**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ: ៤៦/២០១៦ កបធ.សសរ

## សេចក្តីសម្រេច

## ស្តីពីវិសោធនកម្មប្រការ ៨ ថ្មី (ពីរ) និងប្រការ ១០ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្មនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្មនាថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៧
- បានឃើញបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញលេខ ២៤ កបធ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៨
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៥/៩៩ កបធ.សសរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលលើបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ២៥/២០០៧ កបធ.សសរ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ៤៤/២០០៧ កបធ.សសរ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីវិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

# សម្រេច

**ប្រការ១.-**

ប្រការ ៨ ថ្មី (ពីរ) និង ប្រការ ១០ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម :

**ប្រការ ៨ ថ្មី (បី).-**

អនុលោមតាមមាត្រា ២៥ ថ្មី មាត្រា ២៦ និងមាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ វិវាទកម្មដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ។

អនុលោមតាមមាត្រា ៧៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ វិវាទកម្មដែលទាក់ទងក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចសេចក្តីចុងក្រោយ។ បុគ្គលណា ឬ គណបក្សនយោបាយណា ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរជូនក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលចិតសិបពីរ (៧២) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្រុមប្រឹក្សាធម្មនុញ្ញ អាចបើកសវនាការជាសាធារណៈដើម្បីពិនិត្យ និងសម្រេច លើបណ្តឹងជំទាស់ ឬ ត៍វ៉ាក្នុងរយៈពេលដប់ (១០) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

**ប្រការ ១០ ថ្មី (បី).-**

ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តតាមមាត្រា ៣០ ថ្មី មាត្រា ៣១ មាត្រា ៣២ មាត្រា ៣៣ និងមាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងតាមប្រការ ៣ ថ្មី ប្រការ ៤ ប្រការ ៥ ប្រការ ៦ ថ្មី និងប្រការ ៨ ថ្មី (បី) នៃបទបញ្ជាផ្ទៃក្នុងនេះ។

**ប្រការ២.-**

វិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញនេះ ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញអនុម័តនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ នាពេលប្រជុំពេញអង្គរបស់ក្រុមប្រឹក្សា-ធម្មនុញ្ញ ហើយត្រូវបានដាក់ឲ្យអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

អ៊ឹម ឈុនលឹម

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ឯកសារ-កាលប្បវត្តិ